# ឯកសារមូលដ្ឋាន
# សម្រាប់ចាប់ផ្តើម ខប់សែល ដំណាក់កាលទី២

## ការរំលឹកឡើងវិញនូវ ខប់សែល ដំណាក់កាលទី១

នៅដើមឆ្នាំ១៩៩៩ លោកស្រី Caroline Hughes និង លោកស្រី **រៀល សុភាព** នៃ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI បានធ្វើការសិក្សាស្រាវជ្រាវមួយស្តីអំពី លក្ខណៈនិងឫសគល់នៃទំនាស់នៅក្នុងការបោះឆ្នោតនៅកម្ពុជា។ ដោយឈរលើគំហើញនៃការស្រាវជ្រាវនោះ វិទ្យាស្ថាន CDRI បានរៀបចំសន្និសីទថ្នាក់ជាតិមួយ ដើម្បីជំរុញឱ្យមានការព្រមព្រៀងគ្នាក្នុងការចាប់ផ្តើម យន្តការបង្ការទំនាស់ដែលហៅកាត់ថា ខប់សែល (COPCEL which stands for Conflict Prevention in the Cambodian Elections) ដំណាក់កាលទី១ ។ ពីខែ សីហា ឆ្នាំ១៩៩៩ រហូតដល់ខែកញ្ញា ឆ្នាំ២០០៣ មជ្ឈមណ្ឌលដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ (CPD) ដែលជាកម្មវិធីមួយរបស់ CDRI បានរៀបចំការប្រជុំតុមូលប្រចាំខែនៃយន្តការ ខប់សែល ដំណាក់កាលទី១ ចំនួន ៥០ លើក ដោយពុំដែលអាក់ខានម្តងណាឡើយ។ កម្មវិធីនេះបានទទួលការគាំទ្រយ៉ាងពេញទំហឹងពីអង្គការ USAID និង The Asia Foundation ។

ប្រធានបទសំខាន់ៗដែលទាក់ទងទៅនឹងការបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ នៅឆ្នាំ ២០០២ និងការបោះឆ្នោតថ្នាក់ជាតិ នៅឆ្នាំ ២០០៣ ហើយដែលជាប្រភពនៃទំនាស់ បានត្រូវលើកយកមកពិភាក្សាដោយតួអង្គសំខាន់ៗនៃយន្តការបោះឆ្នោតនៅកម្ពុជា។ ជាការពិតណាស់ដែលថា នៅក្នុងយន្តការបោះឆ្នោតនៅកម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត ទំនាស់មួយចំនួននៅពុំទាន់រកដំណោះស្រាយបាននៅឡើយ ព្រោះថាទំនាស់ទាំងនោះមានការទាក់ទិនយ៉ាងចាក់ស្រេះជាមួយសភាពការណ៍នយោបាយ។ ក៏ប៉ុន្តែជាទូទៅ មតិជាតិ និងអន្តរជាតិបានទទួលស្គាល់ថា យន្តការបោះឆ្នោតនៅកម្ពុជាមានការរីកចំរើនឡើងជាលំដាប់ ជាពិសេសក្នុងផ្នែកបច្ចេកទេស ហើយយន្តការខប់សែល បានបណ្តុះឡើងនូវវប្បធម៌នៃការពិភាក្សាគ្នាមួយដោយចំហរ និងដោយមានការចូលរួមពីសំណាក់តួអង្គសំខាន់ៗទាំងអស់។ ប្រទេសថ្មីថ្មោងដូចជា Afghanistan និង East Timor បានបញ្ជូនមន្ត្រីរបស់គេមកជួបជាមួយ មន្ត្រីរបស់វិទ្យាស្ថាន CDRI ដើម្បីសិក្សាស្វែងយល់អំពីយន្តការ ខប់សែល។ វប្បធម៌នៃការពិភាក្សាគ្នានេះ មានសារៈសំខាន់ជាទីបំផុត ជាពិសេសនៅក្នុងបរិបទនៃសង្គមមួយដែលបានឆ្លងកាត់សង្គ្រាមបំផ្លិចបំផ្លាញយ៉ាងខ្ទេចខ្ទាំអស់រយៈពេលជិតបីទសវត្សរ៍ ។ វប្បធម៌នៃការពិភាក្សាគ្នា ត្រូវតែបានទទួលនូវការថែរក្សា ឱ្យបានខ្ជាប់ខ្ជួនជាបន្តទៅទៀត។

## តម្រូវការឱ្យមាន ខប់សែល ដំណាក់កាលទី២

ពីឆ្នាំ២០០៦ រហូតទៅដល់ឆ្នាំ២០០៨ ប្រទេសកម្ពុជានឹងត្រូវរៀបចំការបោះឆ្នោតរហូតដល់ទៅបីលើក។ បោះឆ្នោត

*COPCEL II is financially supported by UNDP*

ព្រឹទ្ធសភានៅដើមឆ្នាំ ២០០៦ បោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ នៅដើមឆ្នាំ ២០០៧ និង បោះឆ្នោតថ្នាក់ជាតិនៅពាក់កណ្តាល ឆ្នាំ ២០០៨។ ដោយមានសហប្រតិបត្តិការពីសំណាក់ លោក ឧិក សេរី សោភក្តិ៍ ដែលជាអ្នកផ្តួចផ្តើមគំនិតបង្កើតយន្តការខប់សែលនេះឡើងកាលពីឆ្នាំ១៩៩៩ CDRI បានជួបធ្វើការពិភាក្សាជាមួយតួអង្គជាដៃគូសំខាន់ៗជាច្រើនមកពីស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ និងដំណាងសហគមន៍អន្តរជាតិ។ CDRI ក៏បានផ្ញើឯកសារធ្វើការស្រង់មតិទៅជូនតួអង្គដ៏ទៃទៀតជាច្រើន ដែលបានឆ្លើយតបមកវិញយ៉ាងសស្រាក់សស្រាំ។ តួអង្គទាំងអស់នោះ បានមានមតិជាឯកច្ឆន្ទថា ដើម្បីរួមគ្នាគ្រប់គ្រង និងបង្ការទំនាស់នៅក្នុងយន្តការបោះឆ្នោតទាំងបីដែលនឹងត្រូវរៀបចំឡើងក្នុងពេលអនាគតដ៏ខ្លីឆាប់ៗខាងមុខនេះ យន្តការខប់សែលត្រូវតែមានដំណើរការបន្តទៅទៀត នៅក្នុងក្របខ័ណ្ឌ ខប់សែល ដំណាក់កាលទី២។

នៅពេលបានទទួលពតិមានអំពីភាពចុះសម្រុងគ្នាក្នុងការបន្តដំណើរការយន្តការ ខប់សែល ដំណាក់កាលទី២ មានអង្គការអ្នកផ្តល់ជំនួយជាច្រើនបានសំដែងការអបអរសាទរយ៉ាងកក់ក្តៅ និងបានធ្វើការធានាផ្តល់ជំនួយដល់យន្តការ ខប់សែល ដំណាក់កាល ទី២។ នៅចុងខែឧសភា ឆ្នាំ២០០៥ អង្គការ UNDP ក៏បានចុះហត្ថលេខាជាផ្លូវការជាមួយ CDRI ដើម្បីបន្តដំណើរការ ខប់សែល ដំណាក់កាលទី២ ក្នុងរយៈពេលបីឆ្នាំ។ នៅដើមខែ មិថុនា ឆ្នាំ ២០០៥ CDRI ក៏បានចុះហត្ថលេខាជាផ្លូវការជាមួយ លោក ឧិក សេរី សោភក្តិ៍ ដើម្បីសុំឱ្យលោកធ្វើជាទីប្រឹក្សាគម្រោងការណ៍នេះ និងធ្វើជាអ្នកសម្របសម្រួល ខប់សែល ដំណាក់កាលទី២ ក្នុងរយៈពេលបីឆ្នាំ។

## យន្តការរបស់ ខប់សែល ដំណាក់កាលទី២

ខប់សែល ដំណាក់កាលទី១ បានផ្តល់នូវបទពិសោធន៍ជាច្រើនដល់ប្រទេសកម្ពុជា ក្នុងការគ្រប់គ្រងនិងបង្ការទំនាស់ក្នុងយន្តការបោះឆ្នោត។ ទាំងបទពិសោធន៍ជាវិជ្ជមាន និងអវិជ្ជមាន សុទ្ធតែបានផ្តល់ដល់យើងនូវមេរៀនដ៏ល្អៗសម្រាប់កែលំអរយន្តការខប់សែលបន្តទៅទៀត។ ក្នុងខប់សែល ដំណាក់កាលទី១ ការជជែកពិភាក្សាធ្វើឡើងនៅថ្នាក់ជាតិ និងនៅទីក្រុងភ្នំពេញ ហើយក៏ពុំបានធ្វើដោយផ្ទាល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយនោះដែរ។ សមាជិកដែលចូលរួមពិភាក្សាមកពីមជ្ឈដ្ឋាន រាជរដ្ឋាភិបាល ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសង្គមស៊ីវិលដ៏ទៃទៀត គណបក្សនយោបាយ និងដំណាងសហគមន៍អន្តរជាតិ។ នៅក្នុង ខប់សែល ដំណាក់កាលទី២ យើងបានបង្កើតនូវរចនាសម្ព័ន្ធជាច្រើនបន្ថែមទៀត ដើម្បីធ្វើឱ្យវប្បធម៌នៃការពិភាក្សាគ្នា បានចុះជ្រៅទៅដល់មូលដ្ឋាន និងជ្រួតជ្រាបឱ្យបានទូលំទូលាយនៅក្នុងជួរប្រជាពលរដ្ឋ។ គឺនៅក្នុងន័យនេះហើយ ដែលយើងបានបំបែក ខប់សែល ដំណាក់កាលទី២ ជាប្រាំមួយរចនាសម្ព័ន្ធ ។

រចនាសម្ព័ន្ធទី១ គឺ **សន្និសីទថ្នាក់ជាតិបើកយន្តការ** (Launching Conference) ដើម្បីចាប់ផ្តើមជាផ្លូវការ នូវយន្តការ ខប់សែល ដំណាក់កាលទី២។ សន្និសីទនេះ គ្រោងរៀបចំឡើងនៅថ្ងៃព្រហស្បតិ ទី១៤ ខែ កក្កដា ឆ្នាំ ២០០៥។

រចនាសម្ព័ន្ធទី២ មានឈ្មោះថា " **ខប់សែល ប្រជុំស្នូល** "/ COPCELCOM (COPCEL Core Meetings)។ ក្នុងកម្រិតនេះ ការប្រជុំធ្វើឡើងមួយខែម្តង ( ឬច្រើនជាងនេះ បើសិនជាមានការស្នើសុំពីសមាជិក ) ដោយមានការចូលរួមពី

សំណាក់អ្នកឯកទេសសុទ្ធសាធ ដែលមានបទពិសោធន៍ និងធ្លាប់ចូលប្រឡូកក្នុងការងារបោះឆ្នោតជាច្រើនឆ្នាំកន្លងរួចមកហើយ។ ក្នុងករិតនេះ សមាជិកខប់សែលទាំងអស់មានចំណេះដឹង និងបទពិសោធន៍ច្បាស់លាស់ អំពីគ្រប់ទិដ្ឋភាពទាំងអស់នៃយន្តការបោះឆ្នោត តាំងពីទិដ្ឋភាពច្បាប់ដែលទាក់ទងនឹងការបោះឆ្នោត រហូតដល់បញ្ហាបច្ចេកទេសនានានៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត។ សម័យប្រជុំលើកទីមួយ នៃ "ខប់សែល ប្រជុំស្នូល" របស់ ខប់សែល ដំណាក់កាលទី២ គ្រោងនឹងរៀបចំឡើងនៅក្នុងខែសីហា ឆ្នាំ ២០០៥។

រចនាសម្ព័ន្ធទី៣ មានឈ្មោះថា " **ខប់សែល ប្រជុំទូលាយ** "/ COPCELEM (COPCEL Enlarged Meetings)។ ក្នុងកម្រិតនេះ ការប្រជុំធ្វើឡើងបីខែម្តង ( ឬញឹកញាប់ជាងនេះ បើសិនជាមានការស្នើសុំពីសមាជិក ) ដោយមានការចូលរួមពីសំណាក់តួអង្គទាំងឡាយ ដែលមានការពាក់ព័ន្ធទៅនឹងយន្តការបោះឆ្នោត។ សម័យប្រជុំលើកទីមួយនៃ "ខប់សែល ប្រជុំទូលាយ" របស់ ខប់សែល ដំណាក់កាលទី២ គ្រោងនឹងរៀបចំឡើងនៅក្នុងខែកញ្ញា ឆ្នាំ ២០០៥។

រចនាសម្ព័ន្ធទី៤ មានឈ្មោះថា " **ខប់សែល ប្រជុំថ្នាក់ខេត្ត-ក្រុង** " / COPCELPROM (COPCEL Provincial Meetings) ។ ក្នុងកម្រិតនេះ យើងសង្ឃឹមថា ក្នុងរយៈពេលជាងបីឆ្នាំខាងមុខនេះ យើងនឹងអាចរៀបចំការប្រជុំយ៉ាងហោចណាស់ចំនួន៤៦លើក ( ឬច្រើនជាងនេះ បើសិនជាមានការស្នើសុំពីសមាជិក និងយោងទៅតាមសភាពការណ៍ជាក់ស្តែងនៅក្នុងខេត្ត-ក្រុងនីមួយៗ ) នៅទូទាំងខេត្ត-ក្រុងទាំង២៤ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សមាជិកដែលចូលរួមប្រជុំនៅក្នុងកម្រិតនេះ មានភាពទូលំទូលាយជាងនៅថ្នាក់ជាតិ ជាពិសេសមកពីសំណាក់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់។ យើងបានប្រមើលឃើញថា ចរន្តនៃសហប្រតិបត្តការជាដៃគូរវាងរាជរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អ្នកផ្តល់ជំនួយ នឹងផ្តល់អាទិភាពកាន់តែខ្លាំងឡើងទៅដល់មូលដ្ឋាន ជាពិសេសទៅដល់តួអង្គទាំងឡាយដែលបំពេញកិច្ចការនៅទីនោះ នៅគ្រប់វិស័យទាំងអស់។ នៅក្នុងបរិបទនេះ យើងមានការជឿជាក់ និងសេចក្តីសង្ឃឹមជាច្រើនទៅលើការពង្រឹង វប្បធម៌នៃការពិភាក្សាគ្នា ព្រោះនេះគឺជាស្នូល និងជាមូលដ្ឋានពិតប្រាកដនៃការអភិវឌ្ឍន៍ ដោយមានប្រជាពលរដ្ឋជាម្ចាស់ការ។ សម័យប្រជុំលើកទីមួយ នៃ "ខប់សែល ប្រជុំថ្នាក់ខេត្ត-ក្រុង" របស់ ខប់សែល ដំណាក់កាលទី២ គ្រោងនឹងរៀបចំឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ សម្រាប់តំបន់ទីមួយដែលមានបួនខេត្ត-ក្រុង គឺ តាកែវ កំពត ក្រុងព្រះសីហនុ និងកំពង់ស្ពឺ។

រចនាសម្ព័ន្ធទី៥ មានឈ្មោះថា " **ខប់សែល តាមរយៈប្រព័ន្ធផ្សព្វផ្សាយ** "/COPCELMED (COPCEL Media) ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះ សាធារណៈមតិបានទទួលស្គាល់ថា ប្រព័ន្ធផ្សព្វផ្សាយមានការរីកចំរើនយ៉ាងខ្លាំង។ វប្បធម៌នៃការពិភាក្សាគ្នាតាមរយៈរលកធាតុអាកាស ក៏មានការរីករាលដាលគួរឱ្យកត់សម្គាល់ជាទីបំផុត។ យើងជឿជាក់ថា ទាក់ទងទៅនឹងយន្តការបោះឆ្នោត មានប្រធានបទខ្លះដូចជាបញ្ហាសន្តិសុខជាដើម តម្រូវឱ្យមានការចូលរួមដ៏ទូលំទូលាយពីសំណាក់សាធារណៈមតិ។ ដូច្នេះ នៅក្នុង ខប់សែល ដំណាក់កាលទី២ យើងមានបំណងនឹងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីលើកដំកើងការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋ នៅក្នុងយន្តការបោះឆ្នោត។ យើងនឹងធ្វើយ៉ាងណាដើម្បីឱ្យប្រជាពលរដ្ឋដែលរស់នៅតាមមូលដ្ឋាន មានឱកាសបានចូលរួមផ្តល់មតិតាមរយៈយន្តការ ខប់សែល។

រចនាសម្ព័ន្ធទី៦ គឺ **សន្និសីទថ្នាក់ជាតិបិទយន្តការ** ដើម្បីបិទជាផ្លូវការនូវយន្តការ ខប់សែល ដំណាក់កាលទី២។ យើងនឹងបូកសរុបលទ្ធផលទាំងអស់ ដោយដកស្រង់នូវមេរៀន និងបទពិសោធន៍នានាដែលទទួលយកបានក្នុងរយៈពេលបីឆ្នាំ ដើម្បីចងក្រងជាឯកសារសម្រាប់ប្រទេសកម្ពុជា សម្រាប់កូនខ្មែរជំនាន់ក្រោយ និងសម្រាប់ប្រទេសដទៃទៀតក្នុងសាកលលោកដែលចង់រៀនសូត្រពីយន្តការខប់សែល។ យើងមានជំនឿយ៉ាងមុតមាំថា ដើម្បីបង្ការ និងគ្រប់គ្រងទំនាស់ដែលកើតឡើងទាំងអម្បាលមាណ ទាំងក្នុងវិស័យបោះឆ្នោត ក៏ដូចជាក្នុងវិស័យដទៃទៀត យើងត្រូវការពេលវេលា និងឆន្ទៈដ៏មុះមុតរបស់តួអង្គទាំងអស់ដែលជាប់ពាក់ព័ន្ធទៅនឹងទំនាស់ទាំងនោះ។ វប្បធម៌នៃការពិភាក្សាគ្នា ដែលជាផ្នែកស្នូលមួយនៃវប្បធម៌កសាងសន្តិភាព ជាកត្តាគ្រឹះក្នុងការស្វែងរកដំណោះស្រាយនានា ដែលភាគីទំនាស់ទាំងអស់មានអារម្មណ៍ និងទំនុកចិត្តថា អាចទទួលយកបាន។ តាមរយៈយន្តការ ខប់សែល វិទ្យាស្ថាន CDRI បានប្រឹងប្រែងបង្កើតនូវវេទិកាមួយ ដែលមានលក្ខណៈអព្យាក្រឹតពិតប្រាកដ ដើម្បីឱ្យតួអង្គទាំងអស់បានកសាងរួមគ្នា ប្រកបដោយអារម្មណ៍សុខសាន្តគ្មានការភ័យខ្លាច នូវវប្បធម៌នៃការពិភាក្សាគ្នា ដើម្បីបង្ការនិងគ្រប់គ្រងទំនាស់នៅក្នុងយន្តការបោះឆ្នោតនៅប្រទេសកម្ពុជា។ យើងមានជំនឿយ៉ាងមុតមាំថា ការដោះស្រាយទំនាស់ ចាប់ផ្តើមឡើងពីការជជែកដោយចំហរអំពីទំនាស់ទាំងនោះ ដោយការគោរពជំហរនិងមតិគ្នាទៅវិញទៅមក ហើយការចាប់ផ្តើមជជែកអំពីទំនាស់នៅក្នុងថ្ងៃនេះឬនាពេលបច្ចុប្បន្ន ក៏គឺដើម្បីធ្វើដំណើររួមគ្នាឈានទៅរកដំណោះស្រាយនៅថ្ងៃស្អែកឬនាពេលអនាគត។

COPCEL II is financially supported by UNDP